ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៣៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមូលនិធិបរិស្ថាននិងសង្គម

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញ អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងបង្កើត "មូលនិធិបរិស្ថាននិងសង្គម" ដែលសរសេរជាអក្សរកាត់ថា "ម.ប.ស." ដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងការទទួលខុសត្រូវរបស់ "គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម" ដែលសរសេរជាអក្សរកាត់ថា "គ.ម.ប.ស."។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែង "មូលនិធិបរិស្ថាននិងសង្គម" ឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដើម្បីស្តារបរិស្ថានឡើងវិញ គាំពារបរិស្ថាន អភិរក្សជីវៈចម្រុះ និងប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប មាននិរន្តរភាព និងការរស់នៅដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើសកម្មភាពទាក់ទងនឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម។

## ជំពូកទី២
## ការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម

**មាត្រា៤.-**

មូលនិធិបរិស្ថាននិងសង្គម ស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ដែលមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងបរិស្ថាន | ១រូប | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| - តំណាងក្រសួងបរិស្ថាន | ១រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានគាំពារបរិស្ថាន | ១រូប | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥.-**

គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- កំណត់នូវគោលនយោបាយនិងយុទ្ធសាស្ត្រប្រមូល គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិ

បរិស្ថាននិងសង្គម

- ជំរុញម្ចាស់គម្រោងឱ្យបង់មូលនិធិបរិស្ថាននិងសង្គម
- ចាត់វិធានការរដ្ឋបាលនិងផ្លូវច្បាប់ ក្នុងការប្រមូលមូលនិធិបរិស្ថាននិងសង្គមពីម្ចាស់គម្រោង ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន
- ធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជន ក្នុងការកៀរគរមូលនិធិបរិស្ថាននិងសង្គម
- ពិនិត្យ និងសម្រេចលើគម្រោងចំណូល ចំណាយរបស់មូលនិធិសម្រាប់បម្រើឱ្យការស្តារបរិស្ថានឡើងវិញ ការគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របមាននិរន្តរភាព និងការរស់នៅដោយចីរភាព
- គ្រប់គ្រង ប្រើប្រាស់ និងបែងចែកមូលនិធិដែលទទួលបានពីគម្រោងអភិវឌ្ឍន៍ឯកជន និងសាធារណៈ
- ពិនិត្យសម្រេចសំណើសុំប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម សម្រាប់បម្រើដល់វិស័យបរិស្ថាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម ដែលបានផ្តល់ឱ្យ
- ធ្វើការណែនាំបច្ចេកទេសលើការគ្រប់គ្រង និងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម សម្រាប់គម្រោងបម្រើវិស័យបរិស្ថាន
- ធ្វើរបាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍វឌ្ឍនភាពរបស់មូលនិធិបរិស្ថាននិងសង្គមរៀងរាល់ត្រីមាស ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៦.-**

គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម មានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគាំពារបរិស្ថាន។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា៧.-**

គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថានសម្រាប់ដំណើរការការងារ។

## ជំពូកទី៣
## ប្រភពចំណូលនិងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម

**មាត្រា៨.-**

ម.ប.ស មានប្រភពចំណូលមកពី៖

- បុព្វលាភពីម្ចាស់គម្រោងអភិវឌ្ឍន៍ឯកជននិងសាធារណៈ ដែលមានចែងនៅក្នុងផែនការគ្រប់គ្រង

បរិស្ថាននៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន

- ប្រាក់ចំណូលពីកិច្ចគាំពារបរិស្ថាន សេវាប្រព័ន្ធអេកូឡូស៊ីនិងអភិរក្សជីវៈចម្រុះ
- អំណោយ ឬជំនួយថវិកា សម្ភារៈ ឧបករណ៍នានាពីសប្បុរសជន ដៃគូអភិវឌ្ឍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា
- កម្រៃសេវាផ្សេងៗពីវិស័យបរិស្ថាន
- ប្រភពផ្សេងៗទៀត។

**មាត្រា៩..**

ម.ប.ស ត្រូវរក្សាទុកក្នុងគណនីមួយរបស់រតនាគារជាតិ ឬធនាគារពាណិជ្ជជាដៃគូណាមួយ តាមការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០..**

មូលនិធិបរិស្ថាននិងសង្គម ត្រូវប្រើប្រាស់ក្នុងសកម្មភាព ដូចខាងក្រោមៈ

- ការគាំពារបរិស្ថាន ការអភិរក្សព្រៃឈើ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ប្រកបដោយនិរន្តរភាព និងការរស់នៅប្រកដោយចីរភាព
- ការស្តារបរិស្ថាននិងកែលម្អធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីឡើងវិញ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនដែលរស់ក្នុងនិងក្បែរតំបន់គម្រោងអភិវឌ្ឍន៍ ឬតំបន់ផ្សេងទៀត
- ការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី
- ការស្រាវជ្រាវបច្ចេកទេសនិងវិទ្យាសាស្ត្រលើវិស័យបរិស្ថាន
- ការផ្សព្វផ្សាយអំពីវិស័យបរិស្ថាន
- ទ្រទ្រង់កម្មវិធីបង្កើតសហគមន៍ការពារធម្មជាតិនិងសហគមន៍នានាបម្រើឱ្យវិស័យបរិស្ថាន
- ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យបរិស្ថាននិងធនធានធម្មជាតិ
- ការអប់រំផ្សព្វផ្សាយលើតំបន់ការពារធម្មជាតិ។

**មាត្រា១១..**

នីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូល និងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១២..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ